# LYNN PUBLIC SCHOOLS

James Leo McGuinness អគាររដ្ឋបាល – 100 Bennett Street, Lynn, MA 01905
ទូរសព្ទ (781) 477-7220 ~ ទូរសារ (781) 477-7312

**ជូនចំពោះ៖** **មាតាបិតា/អាណាព្យាបាល**

**ពី៖** **Lynn Public Schools**

**កាលបរិច្ឆេទ៖** **ថ្ងៃទី ___ ខែវិច្ឆិកាឆ្នាំ 2020**

**កម្មវត្ថុ៖** **ការថតសំឡេង/វីដេអូ និងការថតរូបមេរៀនដោយបុគ្គលិក Lynn Public Schools**

---

ជារឿយៗក្នុងអំឡុងពេលបច្ចុប្បន្ននៃការសិក្សាពីចម្ងាយ បុគ្គលិក Lynn Public Schools អាចធ្វើការថតសំឡេង/វីដេអូមេរៀនសម្រាប់គោលបំណងបណ្តុះបណ្តាលគ្រូបង្រៀន ការអភិវឌ្ឍវិជ្ជាជីវៈ និងសម្រាប់គោលបំណងវាយតម្លៃអ្នកអប់រំ។ ដោយសារហេតុផលដូចគ្នានេះ រូបថត និងរូបថតអេក្រង់អាចត្រូវបានថតដោយបុគ្គលិក Lynn Public Schools ក្នុងអំឡុងមេរៀនពីចម្ងាយ។

មិនមានសិស្សណាម្នាក់នឹងត្រូវបានផ្តោតនៅក្នុងការថតទាំងនេះឡើយ ហើយវាមិនរាប់បញ្ចូលព័ត៌មានសិស្សដែលសម្ងាត់ ឬអាចកំណត់អត្តសញ្ញាណផ្ទាល់ខ្លួននោះទេ។

ការថត រូបថត ឬរូបថតអេក្រង់ទាំងនេះ នឹងត្រូវបានប្រើប្រាស់សម្រាប់គោលបំណងអប់រំប៉ុណ្ណោះ ហើយនឹងមិនត្រូវបានចែករំលែកឡើយ លើកលែងតែតាមរយៈប្រព័ន្ធដែលអាចចូលប្រើបានដោយពាក្យសម្ងាត់សម្រាប់បុគ្គលិក Lynn Public Schools។

**បើសិនជាអ្នកមានសំណួរ ក្តីកង្វល់ ឬការជំទាស់ណាមួយចំពោះចំណុចខ្លឹមសារខាងលើ សូមជូនដំណឹងដល់នាយកសាលា។**